# សហព័ន្ធស្រូវអង្ករកម្ពុជា
# Cambodia Rice Federation

# ឆមាសទីមួយ ឆ្នាំ២០២១ អង្ករកម្ពុជាជាង ២៨ម៉ឺនតោន គិតជាទឹកប្រាក់ជាង ២០០លានដុល្លារ ត្រូវបាននាំចេញទៅកាន់ទីផ្សារអន្តរជាតិ

## The First Semester of 2021, Cambodia exported about 280,000 Metric Ton, worth more than $ 200 million



## របាយការណ៍សង្ខេបការនាំចេញអង្កររបស់កម្ពុជា ឆមាសទី១ ឆ្នាំ២០២១

### SUMMARY REPORT OF CAMBODIA'S RICE EXPORT FIRST SEMESTER 2021

ឆមាសទី១ ឆ្នាំ២០២១នេះ កម្ពុជាបាននាំចេញអង្ករទៅកាន់ទីផ្សារគោលដៅទាំង៤៩ នៅលើសកលលោក ក្នុងបរិមាណអង្ករសរុបចំនួន ២៨០ ៤៥០តោន ដែលគិតជាទឹកប្រាក់ចំនួន ២០២.៦៧ លានដុល្លារសហរដ្ឋអាមេរិក។ ការនាំចេញក្នុងឆមាសទី១នេះបានធ្លាក់ចុះប្រមាណជា ២៩.៤៧% បើធៀបទៅរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០ តែមានបរិមាណប្រហាក់ប្រហែលគ្នាទៅរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៧ ២០១៨ និង ២០១៩។

ចំពោះទឹកប្រាក់នៃការនាំចេញក៏បានធ្លាក់ចុះចំនួន ២៣.៧១% ផងដែរ ដែលឆ្នាំ២០២០ ក្នុងឆមាសទី១ ទទួលបានទឹកប្រាក់ ២៦៥.៦៦លានដុល្លារ មកត្រឹម២០២.៦៧លានដុល្លារនៅឆមាសទី១ ឆ្នាំ២០២១នេះ ។ ការធ្លាក់ចុះទាំងបរិមាណនិងតម្លៃ គឺដោយសារតែបញ្ហាប្រឈមលើការដឹកជញ្ជូន កង្វះសំបកកុងតែន័រ ជាពិសេសទៅកាន់ទីផ្សារសហគមន៍អឺរ៉ុប ធ្វើឱ្យតម្រូវការនិងតម្លៃលក់នាំចេញ នៅត្រឹមកំពង់ផែរបស់អង្ករក្រអូបកម្ពុជា បានធ្លាក់ចុះយ៉ាងគំហុក ពីតំលៃមធ្យមប្រមាណ ៩០០ដុល្លារ មកត្រឹមតម្លៃប្រហាក់ប្រហែល ៧៣០ដុល្លារ ក្នុងមួយតោនតែប៉ុណ្ណោះ។ (តទៅទំព័រទី២)

សម្រាប់ទីផ្សារដែលកម្ពុជា បាននាំអង្ករទៅកាន់នៅក្នុង ឆមាសទី១ នៃឆ្នាំ២០២១គឺមាន ប្រទេសនាំមុខចំនួន៥ រួមមាន ១). ប្រទេសចិន និងតំបន់ស្វយ័តហុងកុង ម៉ាកាវ បាននាំចេញចំនួន ៥១.០៩% ស្មើនឹង ១៤៣ ២៩៣ តោន ២). ប្រទេសបារាំង ១០.៥០% ស្មើនឹង ២៩ ៤៣៤ តោន ៣). ប្រទេសហ្គាប៊ុង ៧.៩៣% ស្មើនឹង ២២ ២២៨តោន ៤). ប្រទេស ម៉ាឡេស៊ី ៦.៧៩% ស្មើនឹង ១៩០៣០តោន និងទី៥). ប្រទេសហូឡង់ ៣.៥៤% ស្មើ ៩ ៩២១ តោន។







ដោយឡែក ចំពោះប្រភេទអង្ករនាំចេញក្នុងឆមាសទី១ ឆ្នាំ២០២១នេះដែរឃើញថា អង្ករក្រអូបប្រណីតមាន៣៧.៣៥% អង្ករក្រអូបធម្មតាមាន២៨.៥៦% អង្ករសគ្រាប់វែងមាន២៦% អង្ករចំហុយមាន២% អង្ករសរីរាង្គមាន២% អង្ករបាក់ ៣% អង្ករដំណើប ១.២២ %។

សម្រាប់ខែមិថុនា ឆ្នាំ២០២១នេះ អង្ករសរុបដែលកម្ពុជានាំចេញមានចំនួន៤៧ ៤១៩ តោន ដែលមានការកើនឡើង១៤.១% បើធៀបនឹងខែមិថុនា ឆ្នាំមុន គិតជាទឹកប្រាក់ ៣៣.៦៩លានដុល្លារ ដែលក្នុងនោះ ទីផ្សារប្រទេសចិន និងតំបន់ស្វយ័តមានចំនួន ២២ ៤៥៩ តោន គិតជាទឹកប្រាក់១៥.១៨លានដុល្លារ ដែលតួលេខនាំចេញទៅចិននេះមានកំនើន ១០២% បើធៀបទៅក្នុងខែមិថុនា ឆ្នាំ២០២០ ដែលមានបរិមាណត្រឹម ១១ ១២៤ តោន ។




# The First Semester of 2021, Cambodia exported about 280,000 Metric Ton, worth more than $ 200 million

In the first semester of 2021, Cambodia exported the milled-rice to 49 destinations with the volume 280,450 Metric Ton (MT), and values $ 202.67

It dropped by 29.47% comparing to the same period in 2020, but this volumes of 2021 is almost same as volumes exported in the first six months of year 2017, 2018 and 2019.

And the total value of exports also dropped 23.71%, from $ 265.66 million in 2020 down to $ 202.67 million.

The major challenges of these decreasing were lacking of containers and increasing of freight cost, it affected the orders of premium fragrant rice mainly to EU markets and the dropped selling price (FOB) from averagely $900 in year 2020 to $730 per MT.

The top 5 leading market destinations were 1). China mainland and its Autonomous regions such as Hong Kong and Macau accounted for 51.09%, equivalent to 143,293 MT, 2). France accounted for 10.50% equal to 29 434 MT, 3). Gabon 7.93% equal to 22,228 MT, 4). Malaysia 6.79% equal to 19,030 MT, and 5). The Netherlands 3.54% equal to 9,921 MT.




Moreover, for varieties, 37.35% of the overall exported were premium fragrant rice, following by fragrant rice (SKO) 28.56%, long-grain white rice 26%, parboiled rice 2%, organic rice 2%, broken rice 3%, and glutinous rice 1.22%.




By the way, for June 2021, Cambodia's milled rice were shipped out 47,419 MT, increased by 14.1% comparing to June last year, and generating in the value about $ 33.69 million. China and its autonomous regions such as Hong Kong and Macau are main Market which covers 22,459 MT equal to $ 15.18 million, increased by 102% from 11,124 MT in June 2020.

ប្រភព៖
ទិន្នន័យនៃការនាំចេញសម្រាប់ ខែមករា ដល់ ខែមិថុនា ឆ្នាំ ២០២១
១. អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
២. អគ្គនាយកដ្ឋានគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៣. អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម

Source:
Data of Cambodia's rice export from Jan-June 2021
1. General Directorate of Agriculture (GDA) of Ministry of Agriculture, Forestry, and Fisheries (MAFF)
2. General Department of Customs and Excise of Cambodia of Ministry of Economic and Finance (MEF)
3. General Department of Trade Support Services, Ministry of Commerce (MoC)

## រៀបរៀងដោយ (PREPARED BY)

## លេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា (SECRETARIAT OF CAMBODIA RICE FEDERATION)


## CONTACT US

www.crf.org.kh

សហព័ន្ធស្រូវអង្ករកម្ពុជា Cambodia Rice Federation - CRF

Cambodia Rice Federation @RiceCrf

ព័ត៌មានស្រូវអង្ករកម្ពុជា Cambodia Rice News

សហព័ន្ធស្រូវអង្ករកម្ពុជា Cambodia Rice Federation

Olympia City, Fortune Tower C7, 8th floor, room 819
Address: Street 182, Sangkat Veal Vong, Khan 7 Makara, Phnom Penh, Cambodia
Cambodia Mail Box of CRF office at Fortune Tower C7 : SOHO 819 (Cambodia Rice Federation)